# របាយការណ៍ប្រចាំខែកក្កដា ឆ្នាំ ២០១៦ របស់មន្ទីរអភិវឌ្ឍន៍ជនបទខេត្តព្រះវិហារ

## I. ស្ថានភាពការងាររបស់មន្ទីរ ÷

### 1. ការិយាល័យ រដ្ឋបាល និងកិច្ចការទូទៅ ÷

❖ ស្ថានភាពបុគ្គលិកមន្ត្រីរាជការក្នុងមន្ទីរ

ការងារគ្រប់គ្រងនិងដឹកនាំមន្ទីរមានថ្នាក់ដឹកនាំចំនួន ៤ រូប (ប្រធានមន្ទីរ និងអនុប្រធានមន្ទីរ ០៣ រូប) និងមានការិយាល័យជំនាញចំនួន ១០ ការិយាល័យ ÷

១- ការិយាល័យរដ្ឋបាល និងកិច្ចការទូទៅ
២- ការិយាល័យផែនការ-ស្ថិតិ
៣- ការិយាល័យគណនេយ្យ និងហិរញ្ញវត្ថុ
៤- ការិយាល័យបណ្តុះបណ្តាល និងស្រាវជ្រាវ
៥- ការិយាល័យអភិវឌ្ឍន៍សហគមន៍
៦- ការិយាល័យផ្គត់ផ្គង់ទឹកជនបទ
៧- ការិយាល័យថែទាំសុខភាពជនបទ
៨- ការិយាល័យអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ
៩- ការិយាល័យផ្លូវជនបទ
១០- ការិយាល័យអភិវឌ្ឍន៍ជនជាតិដើមភាគតិច និងមានការិយាល័យអភិវឌ្ឍន៍ជនបទស្រុកចំនួន ០៧ និងក្រុងចំនួន ០១។

#### 1.1. ចំនួនមន្ត្រីរាជការ

| | |
|---|---|
| – សរុប | ÷ ១៨នាក់ |
| – ប្រុស | ÷ ១៤នាក់ |
| – ស្រី | ÷ ០៤នាក់ |
| – ចំនួនប្រពន្ធមន្ត្រីរាជការ | ÷ ០៩ នាក់ |
| – ចំនួនកូន | ÷ ១៩ នាក់ |
| – អវត្តមាន | ÷ គ្មាន |
| – ចំនួនមន្ត្រីរាជការដែលស្ថិតក្នុងភាពទំនេរគ្មានបៀវត្ស | ÷ គ្មាន |
| – ចំនួនមន្ត្រីរាជការផ្ទេរចូល | ÷ គ្មាន |
| – ចំនួនមន្ត្រីរាជការផ្ទេរចេញ | ÷ គ្មាន |
| – ចំនួនមន្ត្រីរាជការក្របខ័ណ្ឌថ្មី | ÷ គ្មាន |
| – ចំនួនមន្ត្រីរាជការបានតំឡើងប្រាក់បំណាច់មុខងារ | ÷ គ្មាន |

- ចំនួនមន្ត្រីរាជការបានតំឡើងឋានៈ ÷ គ្មាន
- ចំនួនមន្ត្រីរាជការចូលនិវត្តន៍ ÷ គ្មាន
- ចំនួនបុគ្គលិកជាប់កិច្ចសន្យា និងបុគ្គលិកបណ្តែត ÷ ២នាក់
- ចំនួនមន្ត្រីរាជការដែលទៅបំពេញបេសកកម្មនៅបរទេស ÷ គ្មាន
- ចំនួនមន្ត្រីរាជការសហការជាមួយកម្មវិធី និងជាដៃគូអង្គការនានា ÷ ៥នាក់

| ល.រ | នាម និងគោត្តនាម | ភេទ | មុខងារ | សហការជាមួយអង្គការ ឬកម្មវិធី |
|---|---|---|---|---|
| ១ | សេង សារី | ប | ប្រធានមន្ទីរ | -គម្រោងឧបត្ថម្ភស្បៀងបន្ថែម-ហិរញ្ញប្បទានបន្ថែម (ADB)<br>- កម្មវិធីផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ ក្រោមជំនួយហិរញ្ញប្បទានយូនីសេហ្វ |
| ២ | ម៉ប់ ជីវិត | ប | អនុប្រធានមន្ទីរ | កម្មវិធីផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ ក្រោមជំនួយហិរញ្ញប្បទានយូនីសេហ្វ |
| ៣ | ញាណ គង់ | ប | មន្ត្រី | - គម្រោងឧបត្ថម្ភស្បៀងបន្ថែម-ហិរញ្ញប្បទាន បន្ថែម (ADB)<br>- កម្មវិធីផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ ក្រោមជំនួយហិរញ្ញប្បទានយូនីសេហ្វ |
| ៤ | ឆាយ សុវណ្ណា | ស | មន្ត្រី | កម្មវិធីផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ ក្រោមជំនួយហិរញ្ញប្បទានយូនីសេហ្វ |
| ៥ | គួន សកល | ប | មន្ត្រី | -កម្មវិធីកែលម្អហេដ្ឋារចនាសម្ព័ន្ធសេដ្ឋកិច្ចជនបទជំហានទី៣/៤ (RIP-III/RIPIV) |

1.2. **ការងារលិខិតចេញ-ចូល**

- ***បានធ្វើទទួលលិខិតចូលក្នុងនោះមាន.***
  - លិខិតចូលពីបណ្តាក្រសួង និងអង្គភាពនានាក្រោមមន្ទីរចំនួន ÷ ២៤លើក
  - លិខិតចូលពីក្រសួង និងបណ្តារអង្គភាពនានាក្រោមឱវាទមន្ទីរចំនួន ÷២លើក
- ***បានធ្វើលិខិតចេញដែលក្នុងនោះមាន:***
  - លិខិតចេញទៅបណ្តារអង្គភាពនានក្រៅមន្ទីរចំនួន ÷ ៩លើក
  - លិខិតចេញពាក់ព័ន្ធស្ថានភាពមន្ត្រីរាជការចំនួន ÷១២លើក
  - លិខិតចេញទូទៅចំនួន ÷ ១លើក
  - លិខិតចេញទៅក្រសួង និងបណ្តាអង្គភាពនានា ក្រោមឪវាទមន្ទីរចំនួន ÷៣លើក
  - លិខិតចេញវិញ្ញាបនប័ត្រវគ្គបណ្តុះបណ្តាលចំនួន ÷0លើក

1.3. **ការងាររដ្ឋបាល និងបុគ្គលិក**

- បានចូលរួមប្រជុំក្រៅខេត្តចំនួន ÷២លើក

- បានចូលរួមប្រជុំក្នុងខេត្តចំនួន ÷១៦លើក
- បានចូលរួមប្រជុំផ្ទៃក្នុងមន្ទីរចំនួន ÷១លើក

1.4. **ការងារបៀវត្ស និងពលកម្ម**

- បើកប្រាក់បៀវត្សខែមិថុនាជូនមន្ត្រីរាជការ
- រៀបចំឯកសារដំឡើងកាំប្រាក់ជូនបានចំនួន ១១រូប
- បានធ្វើលិខិតស្នើសុំបញ្ចូលចំនួនកូនរបស់មន្ត្រីរាជការក្នុងមន្ទីរ
- ការគ្រប់គ្រងបញ្ជីវត្តមានប្រចាំថ្ងៃ
- បញ្ហាផ្សេងៗ។

2. **ការិយាល័យគណនេយ្យ និងហិរញ្ញវត្ថុ**

+ **ប្រភពថវិការដ្ឋផ្តល់**

- **ថវិកាអនុម័តឆ្នាំ២០១៦** ចំនួន ៥២៣,៥០០,០០០៛០០
  - ប្រាក់ជំពូក ៦០ ចំនួន ៧០,០០០,០០០៛
  - ប្រាក់ជំពូក ៦១ ចំនួន ១៧១,៥០០,០០០៛
  - ប្រាក់ជំពូក ៦៤ ចំនួន ២៨១,០០០,០០០៛
  - ប្រាក់ជំពូក ៦៣ ចំនួន ១,០០០,០០០៛
- **ថវិកាចំណាយសម្រាប់ខែកក្កដា ឆ្នាំ២០១៦** ចំនួន ២៣,៥៣៦,០០០៛០០
  - ប្រាក់ជំពូក ៦០ ចំនួន ៤,៩៨៦,០០០៛០០
  - ប្រាក់ជំពូក ៦១ គ្មាន
  - ប្រាក់ជំពូក ៦៤ ចំនួន ១៨,៥៥០,០០០៛០០
  - ប្រាក់ជំពូក ៦៣ គ្មាន
  - បើកឯកសារស្នងថ្លៃសម្ភារៈការិយាល័យឆ្នាំ ២០១៦
  - ធ្វើគម្រោងថវិកាសម្រាប់ចំណាយក្នុងឆ្នាំ ២០១៧
  - ការគ្រប់គ្រងបញ្ជីវត្តមានប្រចាំថ្ងៃ។

3. **ការងារផែនការ និងស្ថិតិ ÷**

- ថ្ងៃទី ២៩ ខែមិថុនា ឆ្នាំ ២០១៦ បានចូលរួមប្រជុំស្តីពី ការងាររដ្ឋបាល និងការងារគ្រប់គ្រងបញ្ជីវត្តមាន របស់មន្ទីរអភិវឌ្ឍន៍ជនបទខេត្តព្រះវិហារ មានអ្នកចូលរួមសរុប១៨នាក់ ស្រី ៤នាក់។
- ថ្ងៃទី ០១ ខែកក្កដា ឆ្នាំ ២០១៦ ចូលរួមកិច្ចប្រជុំពិភាក្សា ស្តីពីការរៀបចំផែនការថវិកាកម្មវិធី ឆ្នាំ ២០១៧ នៅទីស្តីការក្រសួងអភិវឌ្ឍន៍ជនបទ។

- ថ្ងៃទី០៤-០៧ ខែកក្កដា ឆ្នាំ២០១៦ រៀបចំផ្ញើសៀវភៅផែនការថវិកាឆ្នាំ២០១៧ ផ្ញើទៅនាយកដ្ឋានផែនការ និងទំនាក់ទំនងសាធារណៈ នៃក្រសួងអភិវឌ្ឍន៍ជនបទ។
- ការគ្រប់គ្រងបញ្ជីវត្តមានប្រចាំថ្ងៃ។

4. **ការងាររដ្ឋបាលកិច្ច និង សវនកម្ម÷**
   - គ្មានសកម្មភាព

5. **ការងារទំនាក់ទំនងសាធារណៈ**:
   - ថ្ងៃទី ២២ ខែមិថុនា ឆ្នាំ ២០១៦ ចូលរួមក្នុងពិធីអបអរសាទរខួបលើកទី៩ អតីតយុទ្ធជនកម្ពុជា (២១/៦/២០០៧-២១/៦/២០១៦) ក្រោមអធិបតីភាពឯកឧត្តម អ៊ុំ ម៉ារ៉ា អភិបាលខេត្ត និងជាប្រធានកិត្តិយស ស.អ.ក ខេត្តព្រះវិហារ នៅសាលប្រជុំស្នងការដ្ឋាននគរបាលខេត្ត។
   - ថ្ងៃទី ២៩ ខែមិថុនា ឆ្នាំ ២០១៦ ចូលរួមក្នុងកិច្ចប្រជុំសាមញ្ញលើកទី ២៥ របស់ក្រុមប្រឹក្សាខេត្តអាណត្តិទី២ នៅសាលប្រជុំអាគាររដ្ឋបាលសាលាខេត្តព្រះវិហារ ជាន់ទី៣។
   - ថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ២០១៦ បានចូលរួមប្រជុំស្តីពី ការងាររដ្ឋបាល និងការងារគ្រប់គ្រងបញ្ជីវត្តមានរបស់មន្ទីរអភិវឌ្ឍន៍ជនបទខេត្តព្រះវិហារ មានអ្នកចូលរួមសរុប ១៨នាក់ ស្រី ៤នាក់។
   - ថ្ងៃទី ០៦ ខែកក្កដា ឆ្នាំ ២០១៦ ចូលរួមកិច្ចប្រជុំគណៈកម្មការទ្រទ្រង់កីឡាខេត្តព្រះវិហារស្តីពីការរៀបចំបង្កើតគណៈកម្មការទ្រទ្រង់កីឡាថ្មី និងការចូលរួមប្រកួតកីឡាថ្នាក់ជាតិលើកទី ១ នៅសាលប្រជុំខេត្តព្រះវិហារ។
   - ថ្ងៃទី ០៧ ខែកក្កដា ឆ្នាំ ២០១៦ ចូលរួមជាកិត្តិយសក្នុងពិធី អបអរសាទរខួបលើកទី៨ (០៧ កក្កដា ២០០៨-០៧ កក្កដា ២០១៦) នៃការចុះបញ្ជីប្រាសាទព្រះវិហារ ជាសម្បត្តិបេតិកភណ្ឌពិភពលោក ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តម នាយឧត្តមសេនីយ៍ មាស សុភា អគ្គមេបញ្ជាការរង កងយោធពលខេមរភូមិន្ទ មេបញ្ជាការកងទ័ពជើងគោក តំណាងដ៏ខ្ពង់ខ្ពស់ ឯកឧត្តបណ្ឌិតសភាចារ្យ សុខ អាន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅសារមន្ទីរធម្មជាតិសកលសម្តេចតេជោ ហ៊ុន សែន ព្រះវិហារ ភូមិធម្មជាតិសម្តេចតេជោ ឃុំស្រអែម ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ។
   - ថ្ងៃទី ០៨ ខែកក្កដា ឆ្នាំ ២០១៦ ចូលរួមពិនិត្យការតភ្ជាប់ស្ពានដូនម៉ា ស្ទឹងក្រវ៉ាន់ ក្នុងស្រុកជ័យសែន ក្រោមអធិបតីភាព ឯកឧត្តម នាយឧត្តមសេនីយ៍ មាស សុភា អគ្គមេបញ្ជាការរង កងយោធពលខេមរភូមិន្ទ មេបញ្ជាការកងទ័ពជើងគោក ។

- ថ្ងៃទី ០៩ ខែកក្កដា ឆ្នាំ ២០១៦ ចូលរួមក្នុងពិធីបុណ្យរុក្ខទិវា ០៩ កក្កដា ឆ្នាំ ២០១៦ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ព្រះករុណា ព្រះបាទសម្តេច ព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា នៅភូមិធម្មជាតិសម្តេចតេជោ (តំបន់គ១) ឃុំស្រអែម ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ។
- ថ្ងៃទី ១៣ ខែកក្កដា ឆ្នាំ ២០១៦ ចូលរួមកិច្ចប្រជុំគណៈបញ្ជាការឯកភាពរដ្ឋបាលខេត្ត ក្រោមអធិបតីភាពឯកឧត្តម អ៊ុំ ម៉ារ៉ា អភិបាលខេត្ត និងជាប្រធានគណៈបញ្ជាការឯកភាពរដ្ឋបាលខេត្តព្រះវិហារ នៅសាលប្រជុំខេត្តព្រះវិហារ។

## II. សកម្មភាពការងារតាមវិស័យ ÷

### 1. សកម្មភាពផ្លូវជនបទ

- ថ្ងៃទី ៣០ ខែ មិថុនា - ០១ ខែ កក្កដា ឆ្នាំ២០១៦ ចុះត្រួតពិនិត្យផ្លូវថែទាំជាលក្ខណៈខួប មួយខ្សែ ប្រវែង ១៥ គីឡូម៉ែត្រ  នៅស្រុកជ័យសែន ការងារសម្រេចបាន ៧០% ដោយសារអាកាសធាតុប្រែប្រួលធ្លាក់ ភ្លៀងខ្លាំង ដែលជាហេតុធ្វើអោយមានការយឺតយ៉ាវក្នុងការអនុវត្តការងារ ។

### 2. សកម្មភាពបញ្ជីសារពើភ័ណ្ឌផ្លូវជនបទ

#### 2.1. ការចុះស្រង់ទិន្នន័យផ្លូវ

- ថ្ងៃទី ១៦-១៧ ខែ មិថុនា ឆ្នាំ២០១៦ ចុះស្រង់ទិន្នន័យបញ្ជីសារពើភ័ណ្ឌផ្លូវជនបទ ប្រចាំឆ្នាំ ២០១៦ នៅស្រុករវៀង។
- ថ្ងៃទី ២១-២៤ ខែ មិថុនា ឆ្នាំ២០១៦ ចូលរួមវគ្គបណ្តុះបណ្តាល ស្តីពីការប្រើប្រាស់ប្រព័ន្ធគ្រប់គ្រង ទិន្នន័យផ្លូវជបបទ នៅទីស្តីការក្រសួងអភិវឌ្ឍន៍ជនបទ ។

#### 2.2. ការងារធ្វើបច្ចុប្បន្នភាព

- គ្មានសកម្មភាព។

### 3. ការងារផ្គត់ផ្គង់ទឹកជនបទ

- ថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ២០១៦ បានចូលរួមប្រជុំស្តីពី ការងាររដ្ឋបាល និងការងារគ្រប់គ្រងបញ្ជីវត្តមាន របស់មន្ទីរអភិវឌ្ឍន៍ជនបទខេត្តព្រះវិហារ មានអ្នកចូលរួមសរុប ១៨នាក់ ស្រី ៤នាក់។
- ថ្ងៃទី ៤ -៦ ខែ កក្កដា ឆ្នាំ ២០១៦ បានសហការជាមួយអង្គការ ទស្សនៈពិភពលោកប្រចាំស្រុកត្បែងមានជ័យស្តីពីការចុះសិក្សាអណ្តូងខូចចំនួន ១១អណ្តូង(VN6=4អណ្តូង) នៅក្នុងឃុំព្រះឃ្លាំង ឃុំប្រមេរុ និងឃុំពោធិ៍ ស្រុកត្បែងមានជ័យ ខេត្តព្រះវិហារ។

- ថ្ងៃទី ១១-១២ ខែ កក្កដា ឆ្នាំ ២០១៦ បានសម្របសម្រួលចុះជួសជុលអណ្តូងស្នប់ ជូនប្រជាពលរដ្ឋ បានចំនួន ០៥អណ្តូងស្ថិតនៅឃុំថ្មីចំនួន ០៣អណ្តូង និង ឃុំស្រយ៉ង់បាន០២អណ្តូងសហការជាមួយអង្គការទស្សនៈពិភពលោកប្រចាំស្រុកគូលែន ។
- ថ្ងៃទី ១៣-១៤ ខែ កក្កដា ឆ្នាំ ២០១៦ បានបានសហការជាមួយអង្គការទស្សនៈពិភពលោកប្រចាំ ស្រុកជ័យសែនចុះកំណត់ទីតាំងអណ្តូង និងយកនិយាមការបានចំនួនអណ្តូង ០២អណ្តូងនៅឃុំស្អាងសរុបចំនួន ០១អណ្តូង(ភូមិស្អាង) ឃុំ តស៊ូសរុបចំនួន ០១ អណ្តូង(នៅភូមិថ្មី) ឃុំពុទ្រាសរុបចំនួន ០២អណ្តូង ( ភូមិក្រវ៉ាន់=០២អណ្តូង)។

4. **ការងារថែទាំសុខភាពជនបទ**
   - ក្រុមការងារបានចុះរៀបចំ និងប្រមូលទិន្នន័យដំបូងស្តីពីស្ថានភាពអនាម័យ (PVA) នៅតាមភូមិគោលដៅ ពង្រីកថ្មីទាំង ៥ឃុំ ស្មើនឹង ១៨ភូមិ។
5. **ការងារបណ្តុះបណ្តាល និង ស្រាវជ្រាវ ÷**
   - គ្មានសកម្មភាព។
6. **ការងារអភិវឌ្ឍន៍សហគមន៍÷**
   - ថ្ងៃទី ១៧-១៨ ខែ មិថុនា ឆ្នាំ២០១៦ ចុះបើកវគ្គបណ្តុះបណ្តាលពង្រឹងសម្ថភាព គណៈកម្មាធិការអភិវឌ្ឍន៍ភូមិ ឃុំមរកត់ ស្រុក ជាំក្សាន្ត ចំនួន ៦ ភូមិដូចខាងក្រោមនេះ÷ ១/ភូមិ សែនរុងរឿង២ ២/ភូមិសែនរុងរឿង ៣ , ៣/ភូមិសែនរុងរឿង៤, ៥ភូមិ/សែនតេជះ , ៦/ភូមិតេជោមរកត់, ៧/ភូមិ រមុញ មនុស្សសរុប ៣៥ នាក់ ក្នុងនោះមានស្ត្រី ២៥ នាក់។
   - ថ្ងៃទី ២៣ ដល់ថ្ងៃទី២៤ ខែ មិថុនា ឆ្នាំ ២០១៦ ចុះបើកវគ្គបណ្តុះបណ្តាលពង្រឹងសម្ថភាព គណៈកម្មាធិការអភិវឌ្ឍន៍ភូមិ ឃុំទឹកក្រហម ស្រុក ជាំក្សាន្ត ចំនួន ៧ ភូមិដូចខាងក្រោមនេះ÷ ១/ ភូមិសែនរុងរឿង១ ២/ភូមិសែនរុងរឿង៥ , ៣/ភូមិត្រពាំងធំ , ៤/ភូមិចាត់តាំង , ៥/ភូមិអូរក្សាន្ត , ៦ភូមិសង្គមថ្មី , ៧/ភូមិ ទឹកក្រហម មនុស្សសរុប៣៥ នាក់ ក្នុងនោះមានស្ត្រី ១៣ នាក់។
   - ថ្ងៃទី ២៨ ដល់ថ្ងៃទី២៩ ខែ មិថុនា ឆ្នាំ ២០១៦ ចុះបើកវគ្គបណ្តុះបណ្តាលពង្រឹងសម្ថភាព គណៈកម្មាធិការអភិវឌ្ឍន៍ភូមិ ឃុំស្រយ៉ង់ ស្រុក គូលែន ចំនួន ៧ ភូមិដូចខាងក្រោមនេះ÷ ១/ ភូមិស្រយ៉ង់ត្បូង ២/ភូមិស្រយ៉ង់ជើង , ៣/ភូមិរំចេក , ៤/ភូមិសម្បួរ , ៥/ភូមិម្រេច , ៦/ភូមិកោះគេរ្ត៍ , ៧/ភូមិស្នាផ្អែក មនុស្សសរុប ៣៥ នាក់ ក្នុងនោះមានស្ត្រី ១៤ នាក់។
   - បូកសរុបរួម÷ ០៣ វគ្គ ២ស្រុក ០៣ឃុំ ២០ភូមិ មនុស្សសរុបចំនួន ១០៥ នាក់ស្រី ៥២ នាក់

7. **ការងារសេដ្ឋកិច្ចជនបទ÷**

   – គ្មានសកម្មភាព។

8. **ការងារជនជាតិដើមភាគតិច÷**

   – គ្មានសកម្មភាព។

9. **ការងារយេនឌ័រ÷**

   – គ្មានសកម្មភាព។

10. **គម្រោង / កម្មវិធី ÷**

10.1. **កម្មវិធីផ្គត់ផ្គង់ទឹកស្អាត និងអនាម័យ នៅតាមសាលារៀន និងសហគមន៍** (**គាំទ្រថវិកាដោយ** UNICEF)

- ថ្ងៃទី ២១ -២៤ ខែ មិថុនា ឆ្នាំ ២០១៦ បានចូលរួមវគ្គបណ្តុះបណ្តាលគ្រូបង្គោលស្តីពី កម្មវិធីលើកកម្ពស់ អនាម័យ HP នៅខេត្តក្រចេះ ដែលរៀបចំដោយនាយដ្ឋានថែទាំសុខភាពជនបទនៃក្រសួងអភិវឌ្ឍន៍ជនបទ សហការជាមួយអង្គការ UNICEF ដែលមានអ្នកចូលរួមសរុប ៤៣នាក់ ស្រី ១៣នាក់។
- ថ្ងៃទី ០៤-០៥ ខែកក្កដា ឆ្នាំ២០១៦ បានចូលរួមវគ្គបណ្តុះបណ្តាលស្តីពីអភិក្រមប្រកបដោយសុខុដុមនីយកម្ម ក្នុងការផ្ទេរថវិកាដល់ដៃគូរអនុវត្តគម្រោង និតិវិធីហិរញ្ញវត្ថុ និងវិធីសាស្រ្តក្នុងការសរសេររបាយការណ៍ នៅសណ្ឋាគារ ខេមរា ក្រុងបាត់ដំបង។
- ក្រុមការងារបានចុះរៀបចំ និងប្រមូលទិន្នន័យដំបូងស្តីពីស្ថានភាពអនាម័យ (PVA) នៅតាមភូមិគោលដៅ ពង្រីកថ្មីទាំង៥ឃុំស្មើនឹង១៨ភូមិ។

10.2. **ការងារគាំទ្រដោយ** NGOs

- ថ្ងៃទី ២៤ ខែកក្កដា ឆ្នាំ ២០១៦ បានចូលរួមសម្របសម្រួលវគ្គដល់អ្នកសម្របសម្រួលអនាម័យភូមិ ស្តីពីកម្មវិធីសហគមន៍ដឹកនាំអនុវត្តន៍អនាម័យ នៅភូមិតាបស ឃុំ ស្ពៅ ស្រុកសង្គមថ្មី ខេត្តព្រះវិហារ ដែលសហកាជាមួយអង្គការ ការីតាស សាខាខេត្តព្រះវិហារ មានអ្នកចូលរួមសរុប ២០នាក់ ៦នាក់។
- ថ្ងៃទី ៧-៨ ខែ កក្កដា ឆ្នាំ ២០១៦ បានចូលរួមសម្របសម្រួលវគ្គបណ្តុះបណ្តាលដល់នាយកសាលា លោកគ្រូ អ្នកគ្រូ យុវជន ស្តីពី ភាពជាអ្នកដឹកនាំនៃការលើកកម្ពស់អនាម័យជនបទ ដែលមានរៀបចំនៅសាលប្រជុំ កាកបាទក្រហមខេត្តព្រះវិហារ សហការជាមួយជាមួយអង្គការទស្សនៈពិភពលោកប្រចាំស្រុកត្បែងមានជ័យ ដែលមានអ្នកចូលរួមសរុប ៦០នាក់ ស្រី ៣១នាក់៕